# សិលាចារឹកប្រាសាទភ្នំស្រះខ្ទៅ (K.1417)

បុរាណដ្ឋានប្រាសាទភ្នំស្រះខ្ទៅ មានទីតាំងស្ថិតនៅលើភ្នំស្រះខ្ទៅ ភូមិអូរកោះគគីរ ឃុំជ្រាប់ ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលមានចម្ងាយត្រឹមតែប្រមាណ ៥គ.ម. ប៉ែកឦសានទីប្រជុំជនឃុំកកោះ។ ក្នុងពេលបច្ចុប្បន្ននេះ ប្រាសាទភ្នំស្រះខ្ទៅបានបាក់បែកស្ទើរទាំងស្រុងអស់ទៅហើយ នៅសល់តែទួលគរដោយពំនូកឥដ្ឋជាច្រើន ហើយអ្នកស្រុកបានរៀបជាសាឡុំមួយនៅពីលើទួលប្រាសាទបាត់ទៅហើយ។ ទោះជាយ៉ាងនេះក្តី នៅទីនេះគេបានប្រទះឃើញវត្ថុសិល្បៈបុរាណធ្វើអំពីថ្មភក់ជាច្រើន រួមជាមួយថ្មគោលចារឹកមួយផ្ទាំងផងដែរ ដែលគេបានចុះបញ្ជីលេខ K.1417 ហើយសព្វថ្ងៃគោលចារឹកនេះកំពុងរក្សាទុកនៅសារមន្ទីរខេត្តកំពង់ធំ។ តើសិលាចារឹកប្រាសាទភ្នំស្រះខ្ទៅ មានខ្លឹមសារ និងអត្ថន័យយ៉ាងដូចម្តេចខ្លះ?

ថ្មគោលចារឹកនេះ មានចារឹកអក្សរនៅលើជ្រុងចំនួន ៣ (ខាងមុខ ១ជ្រុង និងសងខាងចំនួន ២ ជ្រុង)។ គួរចាប់អារម្មណ៍នោះ អក្សរចារឹកទាំងបីជ្រុងនេះ មានកាលប្បវត្តិមិនដូចគ្នាទេ ពោល គឺ ជ្រុងទី១ និងទី២ ចារឹកជាភាសាសំស្ក្រឹតនៅរវាងចុងស.វ.ទី៧ ក្នុងរជ្ជកាលព្រះបាទស្រីជយវម៌្មទី១ (គ.ស.៦៥៧ - ៦៨១) រីឯជ្រុងទី៣ ចារឹកជាភាសាខ្មែរនៅសម័យអង្គរ ដោយមានបញ្ជាក់កាលបរិច្ឆេទក្នុងឆ្នាំមហាសករាជ ៨៤៥ (ត្រូវនឹងគ.ស.ឆ្នាំ៩២៣) ពោល គឺត្រូវនឹងរជ្ជកាលព្រះបាទស្រីឦសានវម៌្មទី២ (គ.ស.៩២១ - ៩២៨) និងព្រះបាទស្រីជយវម៌្មទី៤ (គ.ស.៩២១ - ៩៤១)។ សិលាចារឹកនេះ រាងជាសទ្ទឹកសីមា ធ្វើអំពីថ្មភក់ មានលម្អដោយក្បាច់នៅត្រង់ផ្នែកខាងលើ ប៉ុន្តែអក្សរបានបែករលុបបាក់អស់ជាច្រើនកន្លែង ធ្វើឱ្យសេចក្តីរបស់សិលាចារឹកមិនពេញលេញចំពោះការបកប្រែទាំងស្រុងនោះឡើយ តែយើងនៅអាចយល់សេចក្តីបាន។ ជ្រុងទី១ មានអក្សរចារឹកចំនួន ១៣ បន្ទាត់, ជ្រុងទី២ មានចំនួន ២១ បន្ទាត់ និងជ្រុងទី៣ មានចំនួន ២៣ បន្ទាត់។

ទោះបីសិលាចារឹកនេះមិនពេញលេញក៏ដោយ ប៉ុន្តែសេចក្តី អថ៌ន័យ និងអថ៌រូប គឺសរសេរបានត្រឹមត្រូវតាមក្បួនអលង្ការសាស្ត្រល្អណាស់។ តាមសេចក្តីដែលបានពណ៌នា យើងអាចដឹងថាប្រាសាទភ្នំស្រះខ្ទៅ ជាប់ពាក់ព័ន្ធជាមួយជំនឿនិកាយវៃស្ណវ (និកាយព្រះវិស្ណុ) ព្រោះផ្នែកដំបូងរបស់សិលាចារឹកបានរៀបរាប់ និងនមស្ការដល់ព្រះវិស្ណុ ជាទេពចម្បងក្នុងចំណោមទេពត្រីមូតិ៌ក្នុងសាសនាហិណ្ឌូ។ ក្នុងសិលាចារឹកនេះ ក៏បានពណ៌នាអំពីព្រះអច្យុត ត្រិវិក្រម ដែលសុទ្ធសឹងជាអវតារ និងជាព្រះនាម ក្នុងចំណោមព្រះនាមរបស់ព្រះវិស្ណុទាំង ១០០០ ព្រះនាម។ គួរកត់សម្គាល់នោះ ម្ចាស់សិលាចារឹកនេះ គឺពិតជាមានចំណេះដឹងយ៉ាងជ្រៅជ្រះក្នុងសាសនាហិណ្ឌូ ជាពិសេស

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់

*គឺក្នុងនិកាយវៃស្ណវ (និកាយព្រះវិស្ណុ) ដោយអ្នកនិពន្ធបានធ្វើបទនមស្ការដល់ព្រះវិស្ណុ និងបង្ហាញព្រះកីត្តិគុណរបស់ព្រះអច្យុត ដែលព្រះហស្តកាន់កងចក្រ និងបានឈានបីជំហាន និងយកឈ្នះលើអសុររាជ ពលី ហើយបានប្រៀបធៀបបង្ហាញគុណសម្បត្តិរបស់ព្រះបាទស្រីជយវម៌្មទី១ ដូចទៅនឹងព្រះវិស្ណុ។*

*អត្ថន័យជារួមនៃសិលាចារឹកជ្រុងទី១ គឺស្លោកទី១ និងទី២ ពណ៌នាអំពីពាក្យនមស្ការដល់ព្រះវិស្ណុ។ ស្លោកទី៣ ដល់ទី៦ ពណ៌នាអំពីគុណសម្បត្តិ ការធ្វើសង្គ្រាមកម្ចាត់សត្រូវក្នុងសមរភូមិ កំពូលមេដឹកនាំ ស្រោចស្រង់ប្រទេស របស់ព្រះបាទស្រីជយវម៌្មទី១។ ស្លោកទី៧ ដល់ទី៩ ពណ៌នាអំពីមន្ត្រីក្នុងរាជ្យព្រះបាទស្រីជយវម៌្មទី១ មាននាមថា "**ស្រីសត្យាស្រយ**" ដែលលោកជាមន្ត្រីស្មោះត្រង់ ជាអ្នកប្រាជ្ញខាងហោរាសាស្ត្រ និងជាអ្នកកសាងប្រតិមាតម្កល់ទុកនៅក្នុងរាជបុរី។ ស្លោកទី១០ ដល់ទី១២ ពណ៌នាអំពីតង្វាយរបស់មន្ត្រី រួមមាន មាស ប្រាក់ ដី វាលស្រែ ជាកម្មសិទ្ធិរបស់ទេវស្ថាន ដែលមិនអាចមាននរណាមកបំពាន ឬកាន់កាប់ធ្វើជាប្រយោជន៍ផ្ទាល់ខ្លួនបាននោះឡើយ។*

*ចំណែក ខ្លឹមសារសិលាចារឹកជ្រុងទី២ ចារឹកជាភាសាសំស្ក្រឹត បែបពាក្យរាយ ពណ៌នាអំពីព្រះវិស្ណុ ព្រះបាទស្រីជយវម៌្មទី១ និងមន្ត្រីសត្យាស្រយ។ ដោយឡែក ជ្រុងទី៣ ពណ៌នាអំពីកាលបរិច្ឆេទនៃការកសាង (៨៤៥ សក. ៧កើត ខែបុស្ស ថ្ងៃពុធ) និងគ្រឿងតង្វាយផ្សេងៗ។*

## **អត្ថបទចារឹក**

### **ជ្រុងទី១**

| | | |
|---|---|---|
| ១. | សុប្រែកយាក្រាជិម្នុះ | ឧប៉ែ្យាខ្វតវ ..វិទ្ធិអោជិម្នុះ |
| | អប្បវត្តំ ...................... | ភូយឡោភូតយេ.........។ |
| ២. | ចក្រែណាច្យុត ឥតី យះ | ត្រិវិក្រែមាក្រាន្តសវលេលោកាន្តះ |
| | វលីមគ្រាងៃកាមជា | មជាតបិឯយាតិវ..។ |
| ៣. | ជិតតនោវម្ភកាមនោ | មាឈ្យតមោភូវិភូតិភាស្វរីតះ |
| | គក្តិ........មហី..យោ | លោកាស្យេកោ.....ងៃកា។ |
| ៤. | និជ..វិតនិរបេក្ស | សមុឲ្យតាសិរណោជិឃំសុរើង |
| | តាក្សាស្រុតិ.................. | និហន្តុ..........ឥនវយ៉្យះ។ |
| ៥. | ..................ក្ម្វត្វ | ក្ម្វត្វាត្វាត្នីយតាំបជាជា |
| | កលិកាលិលុលិតា | ............សមុបក្ក្រុតេ។ |
| ៦. | អាយ៉្យាវត្តវិវង្វ៌ត | ..................ត្រាតវង្គ.. |

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

| | | |
|---|---|---|
| | ត្រីជយវម៌្មត្យទវត | សាជវយេ៌្យាកុរោការមិ។ |
| ៧. | តតិ ចា....ល្បចាឧប | មកិលបិតផល........រ |
| | .............ត្ដ៌ជ្រេជាភ្ញត្យ | ជ្យោតិបិតណិកិសុរីមាន្យះ។ |
| ៨. | ត្រីជយ..........បេន្ទ្រ | ប្រសក្តិសប............ |
| | ត្រីសត្យាត្រយំជាមា | ..........អតិម្ពិបធិ នេវាធិ។ |
| ៩. | ......................... | ...............មា..... |
| | សត្យជ្រេវីមាន | ស្ថាបិតវានបុ......។ |
| ១០. | វជតកានកហាធិត្យ | ត្រាមក្បេត្របកុ.... |
| | ..................ផល.... | ធានមជាត្នបុណ្យេក្សះ។ |
| ១១. | ត្រីជយវម៌្មតិ កិល | សចាលតៃលសហស្រ |
| | ភ្ញត្យយុ......ត្យ..បុណ្យេ | ធាកោជាបិនោហាយ៌្យ។ |
| ១២. | យា............ជាម្នាជ៌ | ឧត្តាធិ ឆ្មចាជ្វយាសុរ.. |
| | ..វេក្យ...........ត្បុក្បមា | ..........យតេ.............។ |
| ១៣. | (រលុបចាត់) | |

**ជ្រុងទី២**

១. ជយត្យ...ត្នវីភ្ញតិសម្ពោ

២. ភវាន្យ......រិធាម្ពុមុ..វះ

៣. ភវា.........ធិតោ....កោ

៤. វាបសត្រ្ថីបតិម្ពូតី......

៥. អាសីឆ្មហោយោក្នេវិជោត...

៦. ចាល...ណាវិមយាវិវាប

៧. វាជន្យទ្វ....ចាឧ..បត្នះ

៨. បន្មាបនោXចាធិសារ....

៩. ប្រសិទ្ធកោត្រប្រតវទ្ធិជ...

១០. ក្បត្រាត្រ...ម្ពុតិក្នតោជា

១១. ធិកន្តទ្រ្វបិយកាង៌កុត្រា

១២. វ្យជេម្ពសត្រីជយវម៌្មនេវះ

*អត្ថបទដោយៈ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគន់*

១៣. ...ស្យៃវរាជយ្យស្យមក្មូត្យេរាជ

១៤. ...ត្តាលាបកោ.....រុជាច្តាភិជន

១៥. ...បនន្យេតិឈានយរីនយជា

១៦. .....ជាក្បិឈ្យាជិតុណាគណាស

១៧. ..........បសមង្គ្មតសត្រីសត្យាត្រ

១៨. [ម]..មិ អស្និធិ កោត្តមត្រីបុ

១៩. ....ចា..រកាមានិ តិភ្វាំតណាន

២០. .......យារវ្តៅ ទេវីវីបុ.......

២១. ......តិរិចាជាភិវាងកិ..........

**ជ្រុងទី៣**

១. ៨៤៥តកា សប្ដមី កោត

២. បុម្យ វុជវារ នុវ្រះចានក

៣. ម្រតេង៍ អញ ត្រីជ...

៤. ត ប្វណ៌..............

៥. អំរី កាល ប្វ៌កាម្រតេង៏

៦. ជកតិ ត្រីបក្ក្រាក្សេត្វ

៧. ន ថាស្តុល ម្វាយិ ច្រាកិ

៨. តុលិ បិយ ប្រតិម្វា វ្រះកា

៩. ម្រតេង៏ អញ្ញ ជារាយន

១០. វ្រះគិរលិង្គ តិ កំលុង៑ កា

១១. ម្រតេង៏ អញ្ញ អ្នា ត ស្ថា

១២. បជា ត ស្រុកិ ភ្នុ វ្រះកា

១៣. ម្រតេង៏ អញ្ញ ជារាយន

១៤. តិ កំលុង៑ កាម្រតេង៏ អញ្ញ

១៥. ត្រីកក្តិរម៌ ស្ថាបជា ត ស្រុ

១៦. កិ ចង្គ្វយិ ស្រុកិ ជេង៏ វ្នំ ជា ផ្វ

១៧. ល ត កាម្រតេង៏ ជកត ត្រីបុណ្វា

*អត្ថបទដោយៈ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

១៨. រីកាកញ្ឈឱយ កាល្បជា
១៩. អមេ រង្គោ ជ្វង ច្រាំ ស្ដោក ជ
២០. ឩ ជ្យជ................យោម្វ
២១. ................ម្វយ ភយ ម្វយ
២២. .......................កាំយាង
២៣. ....................................

## សេចក្ដីប្រែ

### ជ្រុងទី១

១. *សូមឱ្យ (ព្រះអាទិទេព) ដែលមានពន្លឺរស្មីដ៏ត្រចះត្រចង់ បំផ្លាញចោលនូវពល់សត្រូវដែលពោរពេញដោយអំនួត... ដើម្បីសេចក្ដីចម្រើន និងការរួចផុតពីទុក្ខ (អបវគ្គ) របស់លោកទាំងពួង។*

២. *ព្រះអង្គ (ព្រះវិស្ណុ/អច្យុត) ដែលទ្រង់បានកាន់កង់ចក្រ ជាអ្នកដែលបានឈានព្រះបាទបីជំហាន (ត្រិវិក្រម) គ្របដណ្ដប់លើលោកទាំងមូល... ទ្រង់បានបង្ក្រាបស្ដេចពលី (វលី) ដោយមិនបានបង្ខង់ឡើយ។*

៣. *ព្រះអង្គជាអ្នកឈ្នះលើរូបកាយ និងឈ្នះលើកាមតណ្ហា ជាបុគ្គលដែលគេគួរគោរពបំផុត និងមានតេជៈបារមីភ្លឺស្វាង....... ទ្រង់ជាម្ចាស់នៃលោក ដែលមានអំណាចលើផែនដី.....។*

៤. *ដោយមិនគិតពីជីវិតផ្ទាល់ខ្លួន លោកបានលើកដាវឡើងក្នុងសមរភូមិ ដើម្បីកម្ចាត់សត្រូវទាំងឡាយ... ប្រៀបដូចជាគ្រុឌ (តាក្ស្យ) ដែលបំផ្លាញពួកពស់... លោក គឺជាកំពូលនៃអ្នកដឹកនាំ។*

៥. *.. ក្រោយពីបានធ្វើឱ្យតំបន់ទាំងឡាយក្លាយជាកម្មសិទ្ធិរបស់ខ្លួនហើយ លោកបានជួយស្រោចស្រង់ (ពិភពលោក) ដែលកំពុងរវើរវាយដោយសារឥទ្ធិពលនៃយុគកាលដ៏អាក្រក់ (កលិយុគ)។*

៦. *...នៅក្នុងដែនដីអាយ្យាវតី...... ព្រះបាទ **ស្រីជយវម៌្ម (ទី១)** ដែលជាកំពូលក្សត្រ បានទទួលរ៉ាប់រងលើភារៈនៃផែនដីទាំងមូល។*

៧. *... (លោក) ជាអ្នកបម្រើដែលដឹងគុណជានិច្ច ជាទីគោរពរាប់អាននៃពួកអ្នកប្រាជ្ញហោរាសាស្ត្រ (ជ្យោតិស) លោកបានទទួលនូវផលផ្លែផ្កាដែលប្រាថ្នាចង់បាន...។*

៨. ***ព្រះបាទស្រីជយ (វម៌្ម)**...... មន្ត្រីម្នាក់ឈ្មោះ **ស្រីសត្យាស្រយ**....... បានប្រតិស្ឋាន (រូបព្រះ) ចំពោះពួកទេវតា។*

៩. *... (លោក) ដែលមានសេចក្ដីស្មោះត្រង់ បានរៀបចំប្រតិស្ឋានទុកក្នុងបុរី...។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

១០. (លោកបានថ្វាយ) នូវរ៉ែមាស និងប្រាក់ ភូមិ វាលស្រែ និងហ្វូងសត្វពាហនៈ...... ដើម្បីឧទ្ទិស នូវបុណ្យកុសលផលទានទាំងឡាយ។

១១. ក្នុងរជ្ជកាល**ព្រះបាទស្រីជយវម៌្ម (ទី១)** ភ្នំរាប់ពាន់... សេចក្តីល្អ និងបុណ្យកុសលដែលបានធ្វើ ហើយនេះ មិនត្រូវឱ្យអ្នកណាម្នាក់មករំលោភបំពាន ឬដណ្ដើមយកទៅឡើយ។

១២. អ្វីៗទាំងអស់ដែលបានផ្តល់ឱ្យតាមរាជបញ្ជារបស់ព្រះនរបតី... ចំពោះពួកទេវតា... ត្រូវបាន រៀបរាប់ទុកយ៉ាងលម្អិត...។

១៣. (រលុបបាត់)

## ជ្រុងទី២

១. ព្រះអង្គ (ឬសេចក្តីចម្រើន) ដែលកើតចេញពីមហិទ្ធិឫទ្ធិផ្ទាល់ខ្លួន ចូរមានជ័យជម្នះ!

២. ព្រះនាងភវានី... កើតឡើងពីក្នុងទឹក...

៣. ព្រះភវៈ (ព្រះសិវៈ)... ដែលគេយកឈ្នះមិនបាន...

៤. ...រូបព្រះបដិមា ស្រីបតិ (ប្តីរបស់ព្រះនាងស្រី = ព្រះវិស្ណុ)...

៥. ...ធ្លាប់មាននៅក្នុងពិធីបូជាភ្លើង...

៦. ការគ្រប់គ្រង... វីរបុរសនៅក្នុងដែនដី...

៧. ...ផ្កាឈូកនៃព្រះបាទនៃស្តេចទាំងឡាយ...

៨. ...ដែលកើតចេញពីផ្កាឈូក... នៃព្រះបាទ...

៩. ...ព្រាហ្មណ៍ (ទ្វិជៈ) ដែលមានត្រកូលដ៏ល្បីល្បាញ...

១០. ...ដែលកើតចេញពីវង្សត្រកូលដ៏ចម្បង...

១១. ...ដែលមានកិត្តិយសដ៏ស្អាតស្អំ ភាយទៅសព្វទិសទី...

១២. ព្រះបាទ ស្រីជ័យវម៌្មទេវៈ បានឈ្នះ (លើសត្រូវ)...

១៣. ...ជាអ្នកបម្រើនៃរជ្ជកាលរបស់ព្រះអង្គ...

១៤. ...ដែលមានអម្បូរត្រកូលខ្ពង់ខ្ពស់...

១៥. ...សេចក្តីសប្បុរស នយោបាយ វិន័យ និងការផ្តល់ឱ្យ...

១៦. ...ដែលប្រកបដោយគំនរនៃគុណសម្បត្តិ មានភាពពាក់ទាក់ជាដើម...

១៧. ...ត្រូវបានតុបតែងលម្អ លោក ស្រីសត្យាស្រយ...

១៨. ...នៅក្នុង (ទីក្រុង) គោត្តមស្រីបុរៈ នេះ...

១៩. ...ពួកទេវតាទាំងឡាយ...

អត្ថបទដោយ៖ កំ វណ្ណាក់ និងព្រះតេជគុណ អេង សុគង់

២០. ...ដរាបណាមានព្រះនាងទេវីដ៏ប្រសើរ...

២១. ...នៅក្បែរជើងភ្នំ...

### ជ្រុងទី៣

**(បន្ទាត់ទី១ ដល់ ២៣).** មហាសករាជឆ្នាំ៨៤៥ (គ.ស.៩២១) ៧កើត ខែបុស្ស ថ្ងៃពុធ ព្រះបាទកម្រតេងអញគ្រី.....ដែល..... អំពីកាលបុរាណ កម្រតេងជគតគ្រីបុក្ករក្ស បានជូនថាសមួយតុលប្រាក់បីតុល ប្រតិស្ឋានព្រះកម្រតេងអញនារាយណ៍ ព្រះសិវលិង្គ នៅក្នុងទេវស្ថាន។

កម្រតេងអញ មា ដែលបានស្ថាបនានៅស្រុកផ្ទះ (ទួល) ព្រះកម្រតេងអញនារាយណ៍ នៅក្នុងទេវស្ថាន កម្រតេងអញគ្រីគត្តិវម៌ បានស្ថាបនា (សង់) នៅស្រុកចង្វួយ ស្រុកជើងភ្នំ សម្រាប់ជាឈ្នួលដល់ ព្រះកម្រតេងជគតគ្រីបុណ្ឌរីកក្ស ផ្តល់ឱ្យនូវកល្បនា (តង្វាយ) អង្ករ ចំនួន ៥ ថ្លង ស្លោកទំងន់..ជ្យង..យោ..ចំនួនមួយកែ..។

សរុបជារួមមក សិលាចារឹកប្រាសាទភ្នំស្រះខ្ចៅ (K.1417) បានឆ្លុះបញ្ចាំងពីការវិវឌ្ឍផ្នែកអក្សរសាស្ត្រ ជំនឿសាសនា និងនយោបាយខ្មែរបុរាណ ដែលឆ្លងកាត់ចំនួន ២ សម័យកាលផ្សេងគ្នា។ ខ្លឹមសារដើម (ជ្រុងទី១ និងទី២) ជាភាសាសំស្ក្រឹតនាចុងសតវត្សរ៍ទី៧ បង្ហាញពីការគោរពបូជាព្រះវិស្ណុ (និកាយវៃស្ណវ) និងការលើកតម្កើងបុណ្យបារមីរបស់ព្រះបាទស្រីជយវម៌្មទី១ ដោយប្រៀបប្រដូចទៅនឹងតួអង្គព្រះវិស្ណុ ព្រមទាំងមានការកត់ត្រាពីការថ្វាយដីធ្លី ទ្រព្យសម្បត្តិ និងសត្វពាហនៈពីសំណាក់មន្ត្រីស្មោះត្រង់ឈ្មោះ ស្រីសត្យាស្រយ ដល់ទេវស្ថាន។ ចំណែកឯ ខ្លឹមសារជ្រុងទី៣ ជាភាសាខ្មែរនាសម័យអង្គរ (គ.ស.៩២៣) បានបញ្ជាក់ពីការបន្តប្រើប្រាស់ទីតាំងសាសនានេះ ដោយមានការប្រតិស្ឋានប្រតិមាព្រះនារាយណ៍ និងព្រះសិវលិង្គ ព្រមទាំងការថ្វាយគ្រឿងតង្វាយបន្ថែម។ ពោល ទោះបីជាប្រាសាទបានបាក់បែកទាំងស្រុងក៏ពិតមែនក្តី សិលាចារឹកនេះជាភស្តុតាងយ៉ាងសំខាន់ក្នុងការសិក្សាឈ្វេងយល់អំពីការផ្លាស់ប្តូររូបភាពសាសនា និងការគ្រប់គ្រងរដ្ឋតាំងពីសម័យមុនអង្គររហូតដល់សម័យអង្គរ។

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់



រូបលេខ១៖ ទិដ្ឋភាពប្រាសាទភ្នំស្រះខ្ទៅ ក្រោយពេលបាក់រលំ



រូបលេខ២៖ សិលាចារឹកប្រាសាទភ្នំស្រះខ្ទៅ មុនពេលបញ្ជូនទៅកាន់សារមន្ទីរខេត្តកំពង់ធំ



*រូបលេខ៣៖ សំណៅផ្តិតសិលាចារឹកប្រាសាទភ្នំស្រះខ្មៅ ជ្រុងទី១ (ផ្តិតដោយៈ កំ វណ្ណារ៉ា)*



*រូបលេខ៤៖ សំណៅផ្តិតសិលាចារឹកប្រាសាទភ្នំ*

*អត្ថបទដោយៈ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*



រូបលេខ២៥៖ សំណៅផ្តិតសិលាចារឹកប្រាសាទភ្នំស្រះខ្មៅ ជ្រុងទី២ (ផ្តិតដោយ៖ កំ វណ្ណារ៉ា)



រូបលេខ២៦៖ សំណៅផ្តិតសិលាចារឹកប្រាសាទភ្នំស្រះខ្មៅ ជ្រុងទី៣ (ផ្តិតដោយ៖ កំ វណ្ណារ៉ា)

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់